D24668

# អ៊ីសា ខស្នាន និង ឡុង ដានី សម្ភាសន៍ជាមួយ ប្រាក់ ខន (Prak Khoan)

## អ្នកសួរចម្លើយមន្ទីរ ស-២១

## ថ្ងៃ ទី១៧ ខែកក្កដា ឆ្នាំ២០០០

## នៅឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ

**ខស្នាន:** ប្រវត្តិរូបនេះអ្នកណាសរសេរ?

**ខន:** កាលនោះមានប្រធានក្រុមគេ ។

**ខស្នាន:** ខ្ញុំសូមអានអោយលោកពូស្តាប់!

**ខន:** បាទ ។

**ខស្នាន:** ខ្ញុំឈ្មោះ ប្រាក់ ខន អាយុ ២១ឆ្នាំ នាទី មុនជាយុទ្ធជន និងមេក្រុមក្នុងអង្គភាពនិរសា ស-២១ បច្ចុប្បន្នជាយុទ្ធជន ។ អញ្ចឹងត្រូវទេកន្លែងហ្នឹង?

**ខន:** ត្រូវហើយ ។

**ខស្នាន:** ស-២១ នៅកន្លែងណា?

**ខន:** ទួលស្លែងហ្នឹង ។

**ខស្នាន:** លោកពូដឹងថា ស-២១ មានប៉ុន្មានកន្លែង?

**ខន:** ស-២១ មាននៅកន្លែងព្រៃសមួយកន្លែងទៀង ។ អ្នកទោសណាស្រាលៗគេសួរចម្លើយហើយ គេយកទៅដាក់នៅព្រៃស កន្លែងនោះមិនមែនជាគុកអីទេ ជាកន្លែងអប់រំអោយធ្វើស្រែ ។ អ្នកទោសនៅដែរ តែមុននឹងព្រលែងអោយមកអប់រំការងារ ។ ហើយស-២១មួយទៀតនៅទួល-ស្លែង ជាកន្លែងឃុំឃាំង ។

**ខស្នាន:** មានត្រឹមតែពីរហ្នឹងទេ?

ខន: បាទ ។

**ខស្នាន:** ក្នុងនេះសរសេរថា ភូមិកំណើតពូនៅភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុក៥៦ តំបន់៣៣ ភូមិភាគ និរតី ។

D24668

**ខនៈ** បាទ ស្រុកបាទី នៅក្នុងស្រុក៥៦ ក្នុងជំនាន់ ប៉ុល ពត ។

**ខស្នានៈ** ឪពុកឈ្មោះ ប្រាក់ ម៉ន ម្តាយឈ្មោះ ម៉េង វ៉ាន់?

**ខនៈ** បាទ ។

**ខស្នានៈ** ពីមុននៅភូមិក្រាំងលាវ ឃុំក្រាំងលាវ បច្ចុប្បន្នក្តាប់មិនបាន មិនដឹងជានៅឯណាទេ ។ បានន័យថាម៉េច?

**ខនៈ** កាលហ្នុងខ្ញុំចេញពីផ្ទះទៅ អត់បានត្រឡប់មកផ្ទះវិញទេ កាលពី៧៣ មកដល់ ៧៥ ។ អញ្ចឹង អត់ដឹងថារស់ ឬស្លាប់ និងអត់ដឹងថាគាត់ជម្លៀសទៅខាងណាទេ ។

**ខស្នានៈ** ចំណុចនេះ សរសេរថាបងប្អូនប្រាំនាក់ប្រុស៤នាក់ ស្រី១នាក់ ។

**ខនៈ** ត្រូវហើយ ។

**ខស្នានៈ** នៅខែ៤ ឆ្នាំ៧៣ ខ្ញុំចូលបដិវត្តនៅតំបន់៥៦ តំបន់៣៣ ។

**ខនៈ** ក្នុងជំនាន់នោះ បើមិនចូលក៏គេអោយចូលតែទាំងអស់ដែរ ក្នុងជំនាន់នោះគេកែនកម្លាំង គ្មានយុជនណាដែលនៅភូមិទេ ។

**ខស្នានៈ** កាលលោកពូចូលនោះ តើគេបង្ខំពូ ឬមួយពូស្មគ្រ័ចិត្ត?

**ខនៈ** កាលនោះ គេរើសតែម្តង ដូចថា គេថានែ ហ្អែងធំពេញវ័យហើយ ឥឡូវទៅនៅភូមិ ឬនៅស្រុកអញ្ចឹងទៅណា ។

**ខស្នានៈ** នៅមន្ទីរសេដ្ឋកិច្ចស្រុក ៥៦ មន្ទីរនេះនៅកន្លែងណា?

**ខនៈ** មន្ទីរសេដ្ឋកិច្ចវត្តថ្នាត់យើងនេះ ។

**ខស្នានៈ** តាមផ្លូវជាតិនេះ?

**ខនៈ** ក្នុងឃុំត្នោត ស្រុក៥៦ ជាប់ព្រៃកប្បាស ។

**ខស្នានៈ** ម៉េចបានមកចូលកន្លែងនោះវិញ អត់ចូលក្នុងភូមិឃុំខ្លួនឯង?

**ខនៈ** អាហ្នឹងនៅក្នុងស្រុក៥៦ដែរតើ គ្រាន់តែឃុំខុសគ្នា ។

**ខស្នានៈ** ហើយសរសេរថា ចូលតាមរយៈពូខ្ញុំឈ្មោះ សុទ្ធ ជាប្អូនរបស់ឪពុកខ្ញុំ ។ សព្វថ្ងៃពូនេះនៅរស់ទេ?

**ខន:** ស្លាប់ហើយ ស្លាប់ជំងឺ ពេលបែកហើយ ។

**ខស្មាន:** ខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ស៊ីវ ។ ចុះស៊ីវនេះនៅរស់ទេ?

**ខន:** អត់ដឹងបែកគ្នារហូតមកហើយ ។

**ខស្មាន:** នៅខែ៧ ឆ្នាំ៧៣ ចូលធ្វើយោធាស្រុក៥៦ ។

**ខន:** អាហ្នឹងគេចំរាញ់ពីមន្ទីរសេដ្ឋកិច្ចមកវិញ ។

**ដានី:** ដល់គេចំរាញ់យ៉ាងម៉េចទៅ?

**ខន:** គេចុចឈ្មោះតែម្តង ជាយោធាស្រុក ។

**ខស្មាន:** យោធាស្រុកនៅកន្លែងណា?

**ខន:** ដំបូងនៅឃុំត្រពាំងសាប ។

**ខស្មាន:** ឃុំនេះ?

**ខន:** បាទ ។

**ខស្មាន:** កាលហ្នឹងមន្ទីរនៅកន្លែងណាដែរ?

**ខន:** នៅភ្នំតាម៉ៅ នៅភ្នំផ្តៅពុន ខាងលិចភ្នំតាម៉ៅ ។ រួចហើយគេបញ្ជូនទៅវៃនៅត្រាំខ្នារ កងខ្ញុំមិនមែនជាកងស្រួចទេ ជាឈ្លបស្រុកអញ្ចឹងទៅណា ហើយយកបាយអោយគេអីហ្នឹង កាលហ្នឹងមិនទាន់មានកាំភ្លើងអីកាន់ទេ........ ។

**ខស្មាន:** សូមសួរកាត់លោកពូបន្តិច កាលឆ្នាំ៧៣ ពូចូលធ្វើយោធាស្រុក៥៦ អញ្ចឹងតើស្រុកហ្នឹង ខ្មែរក្រហមកាន់កាប់ពីឆ្នាំណាមក?

**ខន:** វាកាន់កាប់តាំងពីឆ្នាំ៧០មក ។

**ខស្មាន:** អត់មានខាងលន់ ណុលកាន់កាប់ទេ?

**ខន:** លន់ ណុល កាន់កាប់តែត្រង់ផ្សារសំរោងយ៉ោង និងត្រាំខ្នារ ហើយខាងភូមិឃុំផ្សេងទៀតសុទ្ធតែខាងខ្មែរក្រហម ។

**ខស្មាន:** នៅខែ១១ ឆ្នាំ៧៣ ពូមករៀនសាលាបច្ចេកទេសយោធានៅភូមិដូង ឃុំក្រាំងយ៉ូវ?

**ខន:** កាលហ្នឹងខ្ញុំនៅយោធាស្រុកហ្នឹង គេវៃត្រាំខ្នារបែកហើយ គេបញ្ជូនខ្ញុំទៅវៃនៅតាមផ្លូវជាតិលេខ៤ នៅតាឡាត់កាត់កង់ ត្រពាំងក្រឡឹង ដល់ទៅគេបញ្ជូនខ្ញុំទៅភូមិថ្មី ភូមិចាស់នៅខាងត្បូងតាឡាត់កាត់កង់ ខ្ញុំទៅភូមិថ្មី ភូមិចាស់នៅខាងត្បូង តាឡាត់កាត់កង់ នៅក្នុងព្រៃប្រកភ្នំ ទៅបានម៉ាថ្ងៃពីរថ្ងៃហ្នឹងអត់មានអីហូបសោះ អញ្ចឹងខ្ញុំទៅសុំពោតតាមផ្ទះដែលប្រជាជនធ្មើបានបន្តិចបន្តួចហ្នឹងយកមកហូបទៅ។ ហើយអោយទៅវៃ អញ្ចឹងយប់ហ្នឹងគេអោយខ្ញុំត្រៀមកម្លាំងចាំផ្លូវគេ ដល់ទៅអត់មានអីស៊ី ខ្ញុំលួចរត់មកយប់ហ្នឹង រត់ពីហ្នឹងមកឡើងកាត់ភ្នំមកមួយយប់ទល់ភ្លឺទាល់តែមកដល់ស្វាយរំចឹកស្វាយរំពារហ្នឹងបានភ្លឺ កាលហ្នឹងសុំបាយតាមវត្តលោក នៅមានវត្ត។

**ដានី:** ពូមកម្នាក់ឯង?

**ខន:** រត់មកគ្នាពីរបីនាក់។

**ដានី:** កាលឆ្នាំណាដែលឡើងទៅវៃហ្នឹង?

**ខន:** ៧៣។

**ខស្មាន:** ពូសុំបញ្ជាក់ម្តងទៀត អាកន្លែងដែលគេបញ្ជូនពូទៅហើយពូរត់មកវិញហ្នឹង នៅភូមិឃុំស្រុកខេត្តណា?

**ខន:** នៅឃុំអូរ ប្រហែលជាស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

**ខស្មាន:** ចុះស្វាយរំចឹក ស្វាយរំពារនៅក្នុងស្រុកខេត្តណា?

**ខន:** អាហ្នឹងដូចជានៅក្នុងស្រុកសំរោងទោង អូរទេ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

**ខស្មាន:** ហើយពេលណាដែលពូទៅរៀនទៅសាលាបច្ចេកទេសយោធា?

**ខន:** ដល់ពេលខ្ញុំមកផ្ទះ កាលនឹងខ្ញុំអត់ហ៊ាននៅផ្ទះទេ ព្រោះខ្លាចគេតាមចាប់ អញ្ចឹងខ្ញុំឡើងវិងទៅកើត ព្រោះមានម្នាក់ប្រាប់ថា ហ្អែងទៅធ្វើទាហាននៅខាងទន្លេវិញ សំបូរស៊ីជាង មិត្តភ័ក្រប្រាប់អញ្ចឹង។ អញ្ចឹងក៏ខ្ញុំមកតាមមិត្តភ័ក្រហ្នឹងមក ហើយខ្ញុំមកចូលនៅអគ្គភាពភូមិភាគពិសេសវិញមិនមែននៅកំពង់ស្ពឺទេ។

**ខស្មាន:** យ៉ាងម៉េចបានគេដាក់ឈ្មោះថា ភូមិភាគពិសេស?

**ខនៈ** កម្លាំងការពារជុំវិញភ្នំពេញក្រុង ក្នុងតំបន់២៥ ខេត្តកណ្តាល ។ កាលហ្នឹងគេអោយខ្ញុំរៀននៅសាលាភូមិដូង រៀនបានពីរបីខែដែរ បានគេបំបែកកម្លាំងហ្នឹងអោយទៅខាងកងកាំភ្លើងធំ ។ កងកាំភ្លើងធំ១៣៨ របស់ភូមិភាគពិសេស កងពល១២ ។

**ខស្មានៈ** ប្រធានកងពលឈ្មោះអី?

**ខនៈ** ឈ្មោះតាណាត ។

**ខស្មានៈ** កាន់កាំភ្លើងធំរយៈពេលប៉ុន្មាន?

**ខនៈ** ខ្ញុំនៅពីចុង៧៣-៧៤-៧៥-៧៦-៧៧ ។

**ខស្មានៈ** រហូតដល់៧៧?

**ខនៈ** បាទ ។ ខ្ញុំវៃកាលហ្នុងចាប់ពីព្រែកហូរហ្នឹងទៅរហូតតាមទន្លេបាសាក់ហ្នឹង មានកោះអន្លង់ចិនស្វាយរលំ ហើយទៅត្រើយកើត ឡើងទៅព្រែកឯងទៅ ច្បារអំពៅទៅ វៃមកដល់៧៤-៧៥ បានគេដកខ្ញុំយកទៅវៃនៅអ្នកលឿង វៃចាប់ពីអ្នកលឿងទៅទល់ក្អមសំណរ វៃជាមួយអាម៉ារីន ។ អញ្ចឹងវៃស្ទាក់អាមេរីនហ្នឹងដាច់ផ្លូវអស់ទៅ ។ គេបញ្ជូនមកវៃនៅអ្នកលឿងប្រហែលជា៧៣ អីហ្នឹង ខាងបូព៌ាវៃនៅត្រើយកើត ដល់វៃបែកទៅគេដកកម្លាំងខ្ញុំទៅត្រៀមនៅក្អមសំណរវិញ ការពារអាម៉េរីនឡើងមកជួយ មកទល់ខែ៤ គេវៃចូលភ្នំពេញ ១៧មេសាហ្នឹងណា៎ គេដកកម្លាំងខ្ញុំពីខាងកោះធំដាក់ឡានមកនៅតាខ្មៅ ត្រង់ផ្សារដើមមៀននេះ ការពារអាម៉ារីនដែរ ។ កាលហ្នុងគេអោយកាន់កាំភ្លើងធំអាស៊ុសន់កែង កាលហ្នុងមិនបានបាញ់អីដែរ គ្រាន់តែត្រៀមការពារ ។ ហើយខ្វះមកនៅតាមទំនប់ព្រែកត្នោតអីហ្នឹងនិងតាមថ្នល់ ការពារប្រជាជនដែលជម្លៀសចេញពីក្រុងភ្នំពេញហ្នឹង ។ ដល់ខែ៦-៧ ឆ្នាំ៧៥ គេអោយកម្លាំងយើងធ្វើស្រែ ធ្វើស្រែយើងនៅម្តុំក្រពៅ ក្រអាត់អាចម៍កុក..... ។

**ខស្មានៈ** អាហ្នុងនៅ ។ ឃុំស្រុកអីដែរ?

**ខនៈ** មិនដឹងជាឃុំស្រុកអីទេ ក្នុងខេត្តកណ្តាលយើងហ្នឹង ប្រហែលជាស្រុកស្អាង ។ ធ្វើស្រែប្រាំងស្រែវស្សាអីហ្នឹង ។

**ខស្មានៈ** យោធាទាំងអស់?

**ខនៈ** បាទ ទាំងអស់ ។

**ខស្មានៈ** គេអោយកាន់កាំភ្លើងទេ ពេលនោះ?

**ខនៈ** កាំភ្លើងមាន ។ ដល់ពេលទៅធ្វើស្រែ កាំភ្លើងដាក់គរម៉ាដុំចោល ។

**ខស្មានៈ** ប្រធានកន្លែងនោះឈ្មោះអី?

**ខនៈ** ភ្លេចហើយ ។

**ខស្មានៈ** នៅកងពលណាដែរ?

**ខនៈ** កងពល១២ ។

**ខស្មានៈ** អញ្ចឹងកងពល១២ មានទាហានច្រើនមែនទែន?

**ខនៈ** ទាហានប្រហែលជា៧-៨ពាន់ ។

**ខស្មានៈ** តាណាគមេគេតែម្តង?

**ខនៈ** បាទ គាត់ជាប្រធានកងពល ។

**ខស្មានៈ** តាណាគមានត្រកូលអីដែរ?

**ខនៈ** អត់ចាំទេ ភ្លេចហើយ ។ ពូតែគេហៅឈ្មោះតាណាគហ្នឹងតែម្តង ។

**ខស្មានៈ** ពូដែលឃើញមុខទេ?

**ខនៈ** ដែល ពេលមកប្រជុំម្តងម្កាលអីហ្នឹង តែដល់អោយបានស្គាល់ បាននិយាយរកអីអត់ទេ ព្រោះជាអ្នកធំនិងអ្នកតូច ។ ពេលធ្វើស្រែហ្នឹង គេដកកម្លាំងខ្ញុំអោយដើររុះផ្ទះ តាមទំនប់បឹងទំពុនហ្នឹង ផ្ទះស័ង្កសី ផ្ទះក្តាហ្នឹង គេថារុះផ្ទះយកចែកប្រជាជន ។

**ខស្មានៈ** កាលហ្នុងពូមកនៅបឹងទំពុនវិញ?

**ខនៈ** បាទ ។ រុះផ្ទះក្បែរចញ្ចើមថ្នល់ ផ្ទះតូចៗហ្នឹង ។

**ខស្មានៈ** បឹងទំពុន នៅម្តុំត្រង់ណាដែលពូនៅ?

**ខនៈ** អត់នៅទេ ធ្វើសកម្មភាពរុះផ្ទះ ។

**ខស្មានៈ** ហើយចុះកន្លែងនៅតែម្តង?

**ខនៈ** អ៊ឺ អត់កំណត់ទេ យប់ត្រង់ណាដេកកន្លែងហ្នឹង ។ អញ្ចឹងរុះផ្ទះណា ដេកផ្ទះហ្នឹង ។

**ខស្មានៈ** ចុះប្រធានពូផ្ទាល់ឈ្មោះអី?

**ខនៈ** ដូចភ្លេចអស់ហើយខ្ញុំ ដូចជាមិនបានចាប់អារម្មណ៍ មិនដឹងជាពីណាពីណីខ្លះទេ ។

**ដានី:** គេអោយរុះផ្ទះឆ្នាំណា?

**ខនៈ** ៧៥ ។ កាលនោះខ្ញុំគ្រាន់តែមានតួនាទីថា អ្នករុះ និងលើកដាក់ឡានអោយគេទេ ។ មិនដឹងជាគេយកទៅចែកនៅស្រុកណា ខេត្តណា ខ្ញុំអត់ដឹងទេ។ គេយកតែស័ង្កសី និងក្តារទេ ។ ពេលនោះក្នុងរយៈពេលខែវស្សារ ។ បន្ទាប់មកគេអោយខ្ញុំមកជីកប្រឡាយ ជីកប្រឡាយនៅភូមិបាគូព្រែកជ្រៃយើងនេះ ។

**ខស្មានៈ** ស្រុកអីហ្នឹង?

**ខនៈ** ដូចជាស្រុកកណ្តាលស្ទឹង ។

**ខស្មានៈ** ឆ្នាំណាដែរ?

**ខនៈ** មិនដឹងជាឆ្នាំប៉ុន្មានទេ ខ្ញុំវាភ្លេចហើយ វាយូរពេកជាងម្ភៃឆ្នាំហើយ ហើយខ្ញុំនិយាយតាមដំណាក់ៗដែលខ្ញុំចាំណាំ ។ ពេលជីកប្រឡាយនោះ មកធ្វើស្រែនៅព្រៃសដែរ នៅវត្តធម្មគីរី ព្រៃសនេះ ។

**ខស្មានៈ** ពីណាប្រធាននៅព្រៃស?

**ខនៈ** អត់ចាំទេ។

**ខស្មានៈ** មានដែលពូឈ្មោះហ៊ុយទេ?

**ខនៈ** ហ៊ុយមាន កាលហ្នុងមានឈ្មោះហ៊ុយ ហ៊ុយហ្នឹងដូចជា ។ ក្រ ។ បធានកងរយ ។

**ខស្មានៈ** ពូមានប្រសាសន៍តទៅទៀតមើល នៅព្រៃសនោះយ៉ាងម៉េចខ្លះ?

**ខនៈ** មកធ្វើស្រែនៅត្រង់ហ្នឹង អត់មានគោ មាននង្គ័លអីទេ ប្រើចបចាំងអស់គ្នា ។

**ខស្មានៈ** ពេលនោះឈ្មោះពូនៅជាអង្គភាពយោធាដដែលទេ?

**ខនៈ** បាទ នៅក្នុងអង្គភាពយោធាដដែល ។

**ខស្មានៈ** មូលហេតុអីបានគេអោយយោធាធ្វើស្រែអញ្ចឹង?

**ខនៈ** កាលហ្នឹងទាហាន អត់មានទៅច្បាំងត្រង់ណាទេ គេក៏អោយធ្វើស្រែទៅ ។

**ខស្មានៈ** ប៉ុន្តែ មិនមែនពូមាននិន្នាការមិនសូវល្អ បានគេអោយទៅធ្វើស្រែនោះ?

**ខនៈ** អត់ទេ ទាហានធម្មតាទេ ទូទៅ ទាំងគេទាំងខ្ញុំអញ្ចឹងហ្នង ។ កាលនោះ ដូចថាខ្ញុំមិនបាន ប្រព្រឹត្តអីខុសឆ្គងច្បាប់ទំលាប់របស់គេហ្នឹង ធ្វើស្រែដូចម៉ាឆ្នាំបុក្ខីឆ្នាំមិនដឹងទេ មើលអានេះមើល (ប្រវត្តិរូប) ឆ្នាំណាខ្ញុំមកនៅ ស-២១?

**ទស្សានៈ** អានេះដាក់ខែ៧ ឆ្នាំ៧៦ ។ ត្រូវទេពូ?

**ខនៈ** ឆ្នាំ៧៦-៧៧ ហ្នឹងហើយមិនដឹង ខ្ញុំធ្វើបាន៥-៦ខែ ប៉ុន្តែពេលនោះខ្ញុំរបួសសើរើ ។

**ទស្សានៈ** របួសសើរើយ៉ាងម៉េច?

**ខនៈ** ខ្ញុំស្លឹកត្រចៀកហ្នឹងក៏ត្រូវគ្រាប់ ក្រោមឃ្លៀកក៏ត្រូវគ្រាប់ ។ ត្រូវគ្រាប់ច្បាំងជាមួយខាង លន់ ណុល ។

**ទស្សានៈ** ត្រូវគ្រាប់កាលពូនៅកន្លែងណា?

**ខនៈ** អានេះ(ស្លឹកត្រចៀក) នៅកោះអន្លង់ចិន យន្តហោះ ។ ហើយអានេះ(ក្រោមឃ្លៀក) នៅកោះអន្លង់ចិនដែរ ។ អញ្ចឹងកាលហ្នុងខ្ញុំកើតរោគស្តឹកមួយចំហៀងខ្លួន ភ្នែកម្ខាងក៏មើលព្រាល ដកដង្ហើមក៏តឹងម្ខាង ។

**ទស្សានៈ** ខាងណា?

**ខនៈ** នេះខាងឆ្វេង ។ ឥឡូវនេះ យូរៗក៏មានម្តងដែរ ។ ហើយគេអោយខ្ញុំទៅដេកពេទ្យ កាលនោះ ពេទ្យមុនីវង្ស ពេទ្យកេតុមាលា គេថតសួត ថតសង្កាក់បេះដូង ថតអីម៉ាចប់ ថតទៅវាអត់ឃើញ អំបែងអីទេ អញ្ចឹងវាអាចប៉ះពាល់នឹងសរសៃ ។ កាលនោះវាមានពេទ្យចិន គេជំនាញៗខាងចាក់ ម្ជុលវិទ្យាសាស្ត្រ ។

**ទស្សានៈ** ជនជាតិចិនតែម្តង?

**ខនៈ** បាទ ។

**ទស្សានៈ** ប្រចាំការនៅពេទ្យណា?

**ខនៈ** ពេទ្យមុនីវង្ស ។ អញ្ចឹងគេចាក់ម្ជុលវិទ្យាសាស្ត្រអោយ ចាក់ដៃ ចាក់ជើង និយាយរួម ម៉ាសាច់ដុំបត់ចុះបត់ឡើងហ្នឹង សៀតថ្ងា អញ្ចឹងករ កំប៉េះគូទអីហ្នឹង ចាក់យូរៗទៅអត់ដឹងថាអន់ ទេ ។

**ទស្សានៈ** ហ្នឹងជនជាតិចិនផ្ទាល់ហ្នង?

**ខន:** បាទ ។

**ខស្មាន:** ចិនច្រើនទេ ធ្វើពេទ្យនោះ?

**ខន:** ពេទ្យនោះ វាមានតាមផ្នែកវា ដូចថាម៉ាផ្នែកមានម្នាក់ពីរនាក់អញ្ចឹងទៅណា ។ ដល់ពេលខ្ញុំដេក ពេទ្យមកទល់វៀតណាមចូលមកហ្នឹង ។

**ខស្មាន:** អញ្ចឹងពូមកនៅស-២១ ក្រោយមកទៅដេកពេទ្យ?

**ខន:** បាទ ។ នៅស-២១ បាន៥-៦ខែដែរ ។

**ដានី:** ដេកពេទ្យហើយ ពូមានទៅវិញទេ?

**ខន:** ដេកពេទ្យទាល់តែវៀតណាមវ៉ៃចូលមកហ្នឹង ។ ពេលដេកពេទ្យ កម្លាំងខ្ញុំដែលនៅសេសសល់ គេបញ្ជូនទៅវ៉ៃនៅវៀតណាម នៅបារិតអី ច្រើនណាស់ ។ អញ្ចឹងកម្លាំងកំបាក់កំបុត គេអោយនៅក្នុងក្រុងអីចឹងទៅណា ។

**ខស្មាន:** ពេទ្យកេតុមាលាទីតាំងនៅត្រង់ណា?

**ខន:** នៅជិតវត្តភ្នំ ពេទ្យនៅរាល់ថ្ងៃហ្នឹង ។

**ខស្មាន:** ពេទ្យនោះ(កេតុមាលា) មានចិនទេ?

**ខន:** មាន ។

**ខស្មាន:** ហើយចុះពេទ្យមុនីវង្ស ទីតាំងនៅត្រង់ណា?

**ខន:** ទីតាំងនៅខាងត្បូងផ្សារថ្មី ។ ពេទ្យរាល់ថ្ងៃនេះ ។

**ដានី:** កាលជំនាន់ប៉ុល ពត មានអ្នករបួសមកដេកពេទ្យហ្នឹងច្រើនដែរ?

**ខន:** ច្រើនណាស់ ជំនាន់ខ្ញុំដេកហ្នឹង វ៉ៃនៅវៀតណាមត្រូវរបួសបញ្ជូនមក ។ ខ្ញុំពិតទែនទៅគេមិនសូវបានមើលខ្ញុំទេ គេគិតតែមើលអ្នករបួសធ្ងន់ៗមកពីវៀតណាម ព្រោះគេវ៉ៃចូលទៅវៀតណាម ។

**ខស្មាន:** ពូចាំបានទេ ពូដេកពេទ្យនោះនៅឆ្នាំណាដែរ?

**ខន:** ៧៧-៧៨ ។

**ខស្មាន:** ពូនៅស-២១ រយៈពេលប៉ុន្មាន?

**ខន:** តាមខ្ញុំស្មានប្រហែលជា៥-៦ខែ ។

**ខស្មាន:** ក្នុងឆ្នាំណាដែរ?

**ខន:** ឆ្នាំ៧៦ឬ៧៧ហ្នឹង ។

**ខស្មាន:** ពូជួយពិនិត្យមើល ជាសីញ៉េលោកពូ ឬមួយគេចេះតែគូស១ៗទៅ ហើយនិងអក្សរនេះ? (បង្ហាញប្រវត្តិរូប)

**ខន:** អក្សរខ្ញុំ ។

**ខស្មាន:** ពូចាំបានទេ អានេះគេអោយពូសរសេរនៅកន្លែងណា?

**ខន:** កាលនោះ បែបគេអោយខ្ញុំផ្ញើប្រវត្តិរូបចូល ស-២១ ។

**ខស្មាន:** ហើយគេយកប្រវត្តិរូបនេះទៅណា?

**ខន:** ខ្ញុំអត់ដឹងទេ ។

**ខស្មាន:** នេះមួយសន្លឹកទៀត ដូចជាអក្សរខុសអាមិញ ហើយដាក់ឈ្មោះ(ឈ្មោះផាន)ស៊ុន ពូស្គាល់ទេ?

**ខន:** អត់ស្គាល់ ។

**ខស្មាន:** ចុះអានេះ អក្សរពូដែរមែនទេ (លើកប្រវត្តិរូបទីពាបង្ហាញ)?

**ខន:** អានេះគេសរសេរអោយ គេវៃក្រដាស់មកអញ្ចឹងគេសួរយើង ហើយគេសរសេរថែម១ អោយ គេសួរយើងណា៎ ។

**ខស្មាន:** ខ្ញុំចង់ដឹងបន្តិចទៀត ពូមកនៅស-២១ គេអោយពូធ្វើអីដែរ?

**ខន:** កាលនោះ គេអោយការពារជុំវិញមន្ទីរនោះ គេយកអ្នកទោសអីដាក់ក្នុង ខ្ញុំនៅការពារក្រៅ ។

**ខស្មាន:** ពូនៅការពារមានស្គាល់ឈ្មោះ ខៀវ ចេស ហៅពៅ គាត់នៅការពារដែរ ស្រុកកំណើត នៅខាងកំពង់ឆ្នាំង?

**ខន:** ភ្លេចអស់ហើយខ្ញុំ មិនមែនថាមិនស្គាល់ទេ តែភ្លេចអស់ហើយ ។ ខ្ញុំចាំច្បាស់តែអាទិតមួយទេ អានោះសក់ក្រញ៉ាញ់ហើយខ្មៅ ។

**ខស្នាន:** មានចាមទេ?

**ខន:** មានអាម៉ានមួយ ។

**ខស្នាន:** ម៉ានស្រុកកំណើតនៅឯណា?

**ខន:** ដូចនៅកោះធំ ។ ចាមអាហ៊្លន ប៉ុន្តែស៊ីសាច់ជ្រូកន្ទើ ។

**ខស្នាន:** ពូស្គាល់ច្បាស់ ម៉ាននោះ?

**ខន:** កាលនោះ ខ្ញុំចាំតែឈ្មោះទេ ប៉ុន្តែតែដល់ចាស់ៗ ទៅមិនដឹងជាមុខយ៉ាងម៉េចទេ ។

**ខស្នាន:** ក្រោយមានពូដំណឹងថាម៉ានទៅណាទេ?

**ខន:** អត់ដែលជួបទេ ។

**ខស្នាន:** រស់ស្លាប់អី ពូដឹងទេ?

**ខន:** កាលជួបខ្ញុំវានៅរស់ តែដល់ក្រោយមកជិតនាំបែកវៀតណាម ក្រែងលោវាស្លាប់រស់..... ។

**ខស្នាន:** ម៉ានធ្វើអី?

**ខន:** ដូចជាប្រធានក្រុម ។

**ខស្នាន:** ក្រុមខាងណា? ខាងអី?

**ខន:** អត់ទេ ម៉ានក្រោយមកគេចាប់ គេចាប់ដាក់ក្នុងមន្ទីរហ្នងដែរ ។

**ខស្នាន:** មានស្គាល់ឈ្មោះដើមទេ?

**ខន:** អត់ទេ ពូគេហៅម៉ានៗ ។

**ខស្នាន:** ប្រធានក្រុមខាងណា?

**ខន:** ខាងការពារ ។ យូរពេកខ្ញុំភ្លេចអស់ហើយ មិនមែនថាមិនប្រាប់ទេ យូរណាស់ ។ ម៉ាននៅការពារជាមួយខ្ញុំហ្នឹង ដូចជាប្រធានកងអីមិនដឹង ។

**ជាទី:** ពូមានដឹងមូលហេតុគេចាប់?

**ខន:** តែចាប់ចូលដល់ហ្នងអត់មានដឹងរឿងគេទេ អត់បានដឹងរឿងគេទេ អត់ហ៊ានជំនុំគ្នាទេ ។ ជិនាន់ នោះ គ្រលំភ្លួយញាក់ក៏មានដែរ គ្រាន់តែពូថា (គាត់ធ្វើស្នូរជីងចក់) ។ នឹកឃើញរាល់ថ្ងៃ ខ្ញុំញ័រ សាច់រាល់ថៃៗ វាអញ្ចេះ ។

**ខន:** អាហ្នឹងការពារក្រែងមានខ្មាំងធ្វើសកម្មភាព មានលលកខ្មោចមានអីមកយំអីចឹងទៅណា ជុំវិញ មន្ទីរ ។ អាហ្នឹងមិនដឹងជាលលកខ្មោចពិតប្រាកដ ឬមនុស្សមកធ្វើទេ ។ អញ្ចឹងពេលខ្ញុំចប់វេនយាម ហើយខ្ញុំមកដេកគេមកហៅ ហៅបន្តិមែនទែន ខ្ញុំភ័យញ័រសាច់ទាល់តឡូវ ។

**ខស្នាន:** សម្លេងពីណាមកហៅហ្នុង ៗ ?

**ខន:** កាលនោះ ឈ្មោះអាផល អាផល វាប្រធានកង អាផលនោះគាមស្តាប់ដំណឹងថាស្លាប់ដែរហើយ ។ វាប្រធានកង ហៅខ្ញុំថា «ខន ខន ខន មកណេះ មកណេះ អោយលឿនឡើង១» ។ ខ្ញុំញាក់សាច់ ដឹងតែគេហៅមានការហើយ ។

**ខស្នាន:** ម៉ោងប៉ុន្មាន?

**ខន:** ប្រហែលជាម៉ោង១២ កំពង់នៅដេក ។ វាហៅទៅ ទៅជិតវាកេះ ទៅប្រកនេះមើល ស្តាប់លលកខ្មោចយំមើល តើមនុស្សឬក៏លលកខ្មោចមែនទែន ។ ខ្ញុំដូចធូរចិត្តបន្តិច និយាយដំបូងខ្ញុំញ័រ១អស់ហើយ កាំភ្លើងកាន់អត់ជាប់ រួចហើយក៏លលកខ្មោចហើរដើលទៅ ។ កាលនោះជុំវិញអត់មានមនុស្សនៅទេ មានតែផ្ទះ ។ ភ័យម្តងនោះ ខ្ញុំភ័យមែនទែនទៅណា ត្រង់ការនារអីក៏ខ្ញុំប្រុងប្រយ័ត្នដែរណា ខ្ញុំខ្លាចប៉ះពាល់បាត់បង់អាយុជីវិត ។ ព្រោះខ្មោចម្តាយខ្ញុំ គាត់ផ្តាំថា កូនឯងទៅធ្វើម៉េចការពាររឿងគេរ៉ូឈ្មោះ រឿងលួចប្រពន្ធគេ កូនក្រមុំគេ ព្រោះយើងចេញទៅធ្វើសឹកធ្វើសង្គ្រាម ។ ដល់អញ្ចឹងខ្ញុំក៏ប្រុងប្រយ័ត្នដែរ រឿងទ្រព្យរបស់គេ រឿងស្រីញី ហើយនិងពាក្យសំដី ព្រោះចូលដល់កន្លែងហ្នឹង ខ្ញុំឃើញដាក់ស្នែងពេក ថ្ងៃហ្នឹងយាមជាមួយគ្នា ស្អែកឡើងគេចាប់ចូលបាត់ ។

**ខស្នាន:** អ្នកដែលគេចាប់នោះ ខុសអី?

**ខន:** អត់ដឹងខុសអីទេ ប៉ុន្តែអាចដឹងថា ចាប់អាមេមុន ហើយអាមេវាអាចឆ្លើយដាក់កូន តាមខ្សែបណ្តាញ ស្រាវជ្រាវតាមឯកសារអញ្ចឹងទៅ ដល់ត្រង់ហ្នុងវាមានវិមានគប់សួរចម្លើយហើយ ព្រោះខ្ញុំនៅខាងក្រៅក៏ខ្ញុំព្រួដែរ ។ ខ្ញុំព្រួគេស្រែកយ៉ូយយ៉ាយនឹងណា ។ វាស្រែកទៅ ខ្ញុំព្រួហើយ ។

**ខស្នាន:** គេវៃ វៃធ្វើយ៉ាងម៉េចខ្លះ? គេធ្វើរបៀបម៉េចខ្លះ?

**ខនៈ** អានេះអញ្ចេះ ដូចក្នុងផ្សារអញ្ចឹង(ផ្ទះគាត់នៅជាប់របងផ្សារ) ដល់កន្លែងក្នុងគេវ៉ៃហើយស្រែកទៅពួហើយ ។ វ៉ៃ ប៉ុន្តែមិនដឹងជាវ៉ៃយ៉ាងម៉េចខ្លះទេ ឮសូរស្រែកអូយៗៗ ។ ខ្ញុំនៅពីក្រៅនៅការពារជុំវិញហ្នឹងណា៎ ។

**ខស្មានៈ** អាកន្លែងវ៉ៃ វ៉ៃនៅក្នុងសាលារៀននោះ ឬនៅកន្លែងណា?

**ខនៈ** នៅខាងៗក្បែរៗនោះ អាតាមផ្លូវជុំវិញនោះ តាមផ្ទះក្បែរៗនោះ ប៉ុន្តែអានោះនៅក្នុងបរិវេណរបង ខ្ញុំនៅក្រៅរបង ។ អារបងសាលានោះម៉ាជាន់ របងក្រៅម៉ាជាន់ ។

**ខស្មានៈ** សូមពូគូរអោយខ្ញុំមើលបន្តិចមើ ។

**ខនៈ** វាអញ្ចេះ ។




សព្វថ្ងៃបែបនៅតែរបងខាងក្នុងទេ ជារបងសាលាពីមុនមក ។ របងក្រៅបង្គោលឈើ ព័ទ្ធខ្សែលួសច្រើនជាន់ណាស់ ខ្ញុំនៅការពាររបងក្រៅ ។ ហើយគេដាក់ភ្លើងអំពូលម៉ែត្រមកក្រោមកផ្លូវ ។

**ខស្មានៈ** លោកពូឃើញអីខ្លះទៀត នៅក្នុងស-២១?

**ខនៈ** អាហ្នឹងវាមានអញ្ចេះ នៅកន្លែងនោះ វាមានក្រុមផ្សេងៗពីគ្នា អ្នកការពារផ្សេង អ្នកសួរចម្លើយផ្សេង អ្នកដៃដល់សម្លាប់ផ្សេង ។

**ខស្មានៈ** ក្នុងក្រុមមួយៗមានគ្នាប៉ុន្មាននាក់?

**ខនៈ** ខ្ញុំអត់ចាំ ។ ត្រង់គេសម្លាប់កន្លែងណាៗខ្ញុំអត់ដឹងទេ ព្រោះពេលគេយកទោសសម្លាប់មានឡានមួយអាជស់ចិនកង់១០ គេដាក់តង់ជិតៗហើយអោយអ្នកទោសចូល ខ្ញុំនៅក្រៅខ្ញុំថីមិនដឹង ។ តែដឹងថាយកទៅដល់ណាអីដល់ណាខ្ញុំមិនដឹងទេ តែត្រង់យកទៅព្រលែងនៅព្រៃសអីមាន ។

**ខស្មានៈ** ហេតុម៉េចបានជាពូដឹងថាមានព្រលែងនៅព្រៃស?

**ខនៈ** ព្រោះថាជួបគ្នា ធ្វើការកាលនៅព្រៃសនោះ ។ ហ្នឹងអាពីមុនៗមកណា៎ មានៗ ឃើញប៉ុន្តែអត់បាននិយាយគ្នាអីទេ ព្រោះខ្ញុំនៅកងសេរី ហើយនោះអត់សេរីទេ ។

**ខស្មានៈ** អ្នកដែលគេយកទៅព្រៃសនោះ ក្រោយមកគេមានសម្លាប់វិញទេ?

**ខនៈ** អត់បានដឹងដែរ ព្រោះខ្ញុំអត់បានទៅទៀត(ទៅព្រៃស) ។

**ខស្មានៈ** ប្រធានខាងសួរចម្លើយឈ្មោះអី?

**ខនៈ** ឈ្មោះហិ គាត់នោះដូចចិន ភ្នែកខ្វាក់ម្ខាង ។

**ខស្មានៈ** ហើយចុះប្រធានខាងការពារ?

**ខនៈ** ដូចជាហិហ្នឹងដែរ ។

**ខស្មានៈ** ហើយចុះខាងយកមនុស្សទៅសម្លាប់?

**ខនៈ** មានប្រធានគេ ខ្ញុំអត់ចាំ ។

**ខស្មានៈ** ពូមានដែលស្គាល់ឈ្មោះទុយ ប៉េង ចាន់?

**ខនៈ** ចាន់? បើចាន់មួយនោះ ខ្ញុំស្គាល់ គាត់ត្រួតបន្ទប់ពីតាឌុចមកនោះ ឈ្មោះតាចាន់ៗខ្ញុំស្គាល់ ។ គាត់នោះចាស់ មុខស្ងួតតែស្រែង ឡើងគ្រមាំងៗ ខ្ពស់ ខ្ពស់ណាស់ ។

**ខស្មានៈ** ចាន់នោះកាន់ខាងអីដែរ?

**ខនៈ** ហ្នុងដូចជាឃើញនៅក្នុងបន្ទប់តាឌុចតាអីហ្នុង ជាជំនិតរបស់គាត់មិនដឹង អីមិនដឹង មិនបានដឹងច្បាស់ដែរ ។ ខ្ញុំមិនបានចាំត្រកូលអីទេ កាលជំនាន់នោះដូចខ្ញុំប្រាក់ ខន មិនបានហៅអញ្ចឹងទេ បើថាខន ខនទទេ បើថាតាចាន់ តាចាន់ ទរទេអញ្ចឹងទៅ ។ គេអត់និយមហៅត្រកូលទេ ។

**ខស្មានៈ** ពូនៅកន្លែងហ្នុង ពូដឹងទេ អ្នកណាដូចថាសាហាវជាងគេ? ដូចថា មិនសូវចេះអាណិត?

**ខនៈ** មានតែអ្នកដៃដល់គេទេ ខាងសម្លាប់ ។

**ខស្មានៈ** ចុះម៉ានយ៉ាងម៉េចដែរ?

**ខនៈ** ម៉ានក៏អញ្ចឹងដែរ ។ ក្រោយមកគេចាប់វិញទៅ មិនដឹងជាយ៉ាងម៉េច ។

**ខស្មានៈ** ម៉ានមានវ៉ៃអ្នកទោសទេ?

**ខនៈ** ម៉ានដូចភ្លេចដែរហើយ ។

**ខស្មានៈ** ហើយចុះឌុច?

**ខនៈ** ឌុចជាប្រធានហើយ ។

**ខស្មាន:** ចុះពូយល់យ៉ាងម៉េចដែរ ថាឌុចនោះជាមនុស្សប្រភេទយ៉ាងម៉េច?

**ខឌ:** អូ ឌុចនោះថាម៉ាត់ណាម៉ាត់ហ្នឹងហើយគ្មានអ្នកណាប្រកែកបានទេ នៅក្នុងអគ្គភាពនោះគ្មានពីណាហ៊ានទៅលេងទៅសើចអីអត់ទេ ។ ហើយខ្ញុំនៅការពារគឺដឹងតែពីការពារ ឃើញដូងគេកាប់ដឹកទឹកសល់ហើយក៏អត់ហ៊ានដែរ កន្ទុយបារីអីក៏អត់ហ៊ានរើសជក់ដែរ បើគាណាគប្រធានកងពលខ្ញុំអាហ្នឹងខ្ញុំហ៊ានរើសជក់ ។

**ខស្មាន:** ការហូបចុករបស់លោកពូនៅស-២១ យ៉ាងម៉េច?

**ខឌ:** ការហូបចុក ព្រលឹមឡើងហូបបបរមួយចានមានឆារត្រកួនជាមួយសៀងអីទៅ ដល់ថ្ងៃ បាយបាយតែម៉ាចានទេ អត់មានលើសទេ ស្លរត្រកួនព្រលិតអីទៅ និងបាយល្ងាច ។

**ខស្មាន:** មនុស្សដែលធ្វើការនៅស-២១ ហើយក្រោយមកត្រូវគេចាប់វិញ តើមានបញ្ហាពីណាអោយចាប់?

**ខឌ:** កាលនោះវាមានបញ្ហាពីលើមក ។

**ខស្មាន:** តើបញ្ហាពីឌុច ឬអ្នកនៅខាងលើឌុច ឬអ្នកមានឋានៈក្រោមឌុច?

**ខឌ:** អានេះ ខ្ញុំគ្រាន់តែស្មានទេ អ្នកធ្វើការនៅហ្នឹងវាអាចល្មៀង ឬមិនទៀងត្រង់ជាមួយគ្នា ។ អញ្ចឹងអាចចាប់អ្នកហ្នឹង ឬទំលាក់កំហុសលើអ្នកហ្នឹង អាហ្នឹងគ្រាន់តែការសន្និដ្ឋានខ្ញុំ ឯការដឹងច្បាស់នោះ ខ្ញុំមិនបានដឹងច្បាស់ការរាក់ជ្រៅទេ ។

**ខស្មាន:** ហើយចុះនិយាយពីអ្នកបញ្ជារ?

**ខឌ:** មានតែឌុចហ្នឹងហើយបញ្ជារ ហ្នឹងគេប្រធានហើយ ។

**ខស្មាន:** មានអ្នកណាក្រៅពីឌុចទៀតទេ?

**ខឌ:** អត់មានទេ ។

**ខស្មាន:** ចុះនៅពីលើឌុចមានអ្នកណា? ដូចថាឌុចទាក់ទងជាមួយអ្នកណានៅខាងលើទៀត?

**ខឌ:** មាន សុន សេន ។

**ខស្មាន:** ម៉េច បានពូដឹងថា សុន សេន?

**ខឌ:** ព្រោះធ្លាប់មកប្រជុំនៅហ្នុង ខ្ញុំការពារ ។

**ខស្មាន:** តែសុន សេន ម្នាក់ទេ?

**ខនៈ** ឃើញតែសុន សេន ម្នាក់ទេ ប៉ុន្តែកាលនោះវាមានវរៈស៊ីគេទៀត ប៉ុន្តែមិនដឹងថាអ្នកណាអ្នកណាខ្លះទេណា៎ ។

**ខស្មាធ:** សុន សេន មកប្រជុំនៅត្រង់ណា?

**ខនៈ** នៅកន្លែងផ្ទះតាឌុចហ្នុង នៅខាងកើតគុក មុំជិតមេភ្លើង ឥឡូវរកមិនឃើញទេ ។

**ខស្មាធ:** មានអ្នកណាក្រៅពីឌុចទេ ដែលជួបសុន សេន?

**ខនៈ** ពិបាកថា គ្រាន់តែខ្ញុំដឹងគោល។បុណ្ណឹង តែកិច្ចការរាក់ជ្រៅ ខ្ញុំមិនបានដឹងទេ ។

**ខស្មាធ:** ពូដែលឃើញសុន សេន ផ្ទាល់ទេ?

**ខនៈ** ឃើញម្តងដែរ ពេលគាត់ដើរចេញ ។

**ខស្មាធ:** សុន សេន ធ្វើអី?

**ខនៈ** គាត់ជាអគ្គមេបញ្ជាការកងទ័ព ។

**ខស្មាធ:** ពូនៅស-២១ ដែលបានឡើងទៅឃើញអ្នកទោសជាប់យ៉ាងម៉េចអីយ៉ាងម៉េចទេ?

**ខនៈ** ឡើង ។ ជូនណាខាងក្នុងខ្ទះកម្ចាំង ខ្ញុំទៅយាមខាងក្នុងម្តងម្កាលដែរ អញ្ចឹងឃើញគេធ្វើបន្ទប់ទទឹងមិនដល់មួយម៉ែត្រទេ ហើយគេដាក់ខ្នោះជាប់នឹងបន្ទប់ និងឡាំងអ៊ែកែងមួយសំរាប់អាចម៍ ។ ប៉ុន្តែ ខ្ញុំឃប់គេអត់អោយចូលក្នុងទេ គេចាក់សោរទាំងអស់អោយនៅខាងក្រៅ គេបិទរបងលើខឿននោះណា៎ ។ អ្នកនោះនៅឆ្ងាយ។ណាស់ ខ្ញុំមិនដែលស្គាល់ទេ ។

**ខស្មាធ:** ដែលជួបនិយាយជាមួយអ្នកទោសទេ?

**ខនៈ** សួរដែរ ។

**ខស្មាធ:** គេអោយពូចូលដែរ?

**ខនៈ** មានអ្នកយាមម្នាក់ពីរនាក់ ហើយយើងដើរចុះដើរឡើង អង្គុកសួរលេងទៅ ។ សួរថាគាឯងមកពីណា ហើយធ្វើស្អីបានគេចាប់ ខ្លះឆ្លើយថាអត់ដឹងរឿងអី ។

**ខស្មាធ:** ចុះពូដែលឃើញរបៀបគេសួរចម្លើយយ៉ាងម៉េចទេ?

**ខនៈ** ខ្ញុំមើលឃើញខ្លះដែរ ព្រោះខ្ញុំនៅជិត គេសួរថា ហ្អែងឈ្មោះអី ស្រុកកំណើតនៅឯណា ចុះហ្អែងមានទំនាក់ទំនងជាមួយអ្នកនេះ។ អ្នកដែលគេចាប់បានមុន។នោះណា ។

**ខស្មាធ:** ទំនាក់ទំនងយ៉ាងម៉េច?

**ខន:** ខ្ញុំទទាហរណ៍ដូចគេចាប់គាណាគមកអញ្ចឹង គាណាគនោះមេ ដល់គេថាគាណាគក្បត់អញ្ចឹងទៅ គេចាប់គាណាគមក រួចហើយគេចាប់ក្រោមគាណាគមក ហើយគេសួរថា នែ កាលមុនហ្អែងធ្លាប់ទាក់ទងជាមួយអ្នកណាទេ គាណាគទេ។ មេនិងកូន មិនទាក់ទងគ្នា ដល់ទាក់ទង ឆ្លើយចុះឆ្លើយឡើង ហើយគេសួរចុចចំណុចអីមួយ គេចាប់ចំណុចនោះណា៎។ ហើយខ្លះក៏អត់មានទំនាក់ទំនងអត់ឆ្លើយ ខ្លះក៏មានប្រវត្តិរឿងគេ ឆ្លើយទៅណា៎ អាហ្នឹងគេស្រាវជ្រាវតាមខ្សែ ហើយគេចាប់តាមខ្សែ។

**ខស្មាន:** គេមានសួរថា តើហ្អែងមានក្បត់អីបានគេចាប់មក គេមានសួរអញ្ចឹងទេ?

**ខន:** ខ្លះក៏សួរចំទៅ ខ្លះក៏សួរចំណុចនេះចំណុចនោះ។ ដែលដឹងរឿងពីមេទៅហើយចំណុចដែលត្រូវ ផ្ដើនៅកន្លែងនេះ កន្លែងនោះទៅណា៎។ អញ្ចឹងគេចុចចំណុចហ្នឹង ខ្លះវាផ្ដើមែនឆ្លើយត្រង់ទៅ ខ្លះក៏ អត់ ក៏អត់ទៅ។

**ខស្មាន:** ហើយចុះបើអ្នកនោះអត់ឆ្លើយ?

**ខន:** អត់ឆ្លើយ គេវៃ គេវៃយូរៗទៅ ទុកចោលទៅ។ តាមអ្នកនេះ គេនិយាយ។

**ខស្មាន:** បាទ។ វៃទុកចោលយ៉ាងម៉េច?

**ខន:** វៃយូរៗទៅអត់បានចម្លើយអីទុកចោលក្នុងគុកទៅណា។ ហើយដល់ពេលបាយអីទៅជុំគ្នានៅគុហ្នឹងទាំងកងការពារអី ដល់ពេលដូនម៉ឺន គេចូលមកស៊ីបាយហើយ ដល់ចូលមកនោះនិយាយគ្នាហើយ តុខាងអ្នកសួរចម្លើយនៅម៉ាដុំទៅ ហើយពួកនិយាយគ្នាហើយ ខ្លះថា ថ្ងៃនេះសួរអត់ដឹងអត់ដឹង ខ្លះសួរថាដឹងអញ្ចឹងទៅណា៎។

**ខស្មាន:** ពេលសួរ គេមានកត់ត្រាអីទេ?

**ខន:** គេអោយម្ចាស់ខ្លួនសរសេរ។

**ខស្មាន:** គេអោយទៅសរសេរកន្លែងផ្សេង ឬយ៉ាងម៉េច?

**ខន:** សរសេរនៅកន្លែងហ្នឹង។

**ខស្មាន:** កន្លែងជាប់គុក?

**ខន:** នៅខាងក្រៅ។ ខ្ញុំបញ្ជាក់ថា ព្រលឹមឡើងម៉ោងធ្វើការ ម៉ោង៧ដល់ម៉ោង១១ គេបណ្ដើរអ្នកទោសយកមកសួរក្នុងផ្ទះបន្ទប់មួយអញ្ចឹងទៅ ហើយឆ្ងាយគ្នាបួនប្រាំផ្ទះបន្ទប់មួយទៀតទៅកុំអោយពួកឮឡាដល់គ្នា ហ្នឹងខ្ញុំឃើញគេបណ្ដើមកអញ្ចឹង ខ្ញុំនៅខាងក្រៅខ្ញុំឃើញអញ្ចឹង បណ្ដើរមក

ដាក់ច្រវ៉ាក់ខ្នោះដៃ ហ៊ុំមុខជិត ហើយមកនៅដល់កន្លែងនេះ គេចាក់ខ្នោះជើង ហើយបើកមុខ ហើយបើកមុខ លែងដៃ ។ ហើយដាក់ប៊ិចមួយក្រដាស់មួយអោយសរសេរ សរសេរហើយគេយកមកមើល ត្រង់ណាដែលគេមើលទៅចាស់ចិត្ត គេសួរហើយណ៎ា ។ ឯកសារខ្ញុំឃើញនៅអារត់អាពាយម៉ាគំនរ ខ្លះគេយកដុតចោល ខ្ញុំឃើញអញ្ចឹង ខ្ញុំយកមើលទៅ ។

**ខស្នាន:** មុននឹងយកអ្នកទោសម្នាក់សម្លាប់ចោល ឬយកទៅព្រៃស អ្នកទោសម្នាក់ត្រូវបានសួរប៉ុន្មានដង?

**ខន:** ខ្ញុំអត់ដឹងទេ ។

**ខស្នាន:** អ្នកទោសនៅកន្លែង ស-២១ គេឃុំរយៈពេលប៉ុន្មាន?

**ខន:** ទេ ខ្ញុំអត់ដឹងទេ ប៉ុន្តែខ្លះ ឃើញនៅរាប់ខែដែរ ។

**ខស្នាន:** អ្នកទោសប្រភេទណាគេអោយនៅយូរ អ្នកទោសប្រភេទណាគេអោយនៅឆាប់?

**ខន:** មិនអាចរ៉ាយរ៉ាប់បាន ពីព្រោះអាហ្នឹង វាមិនបានដឹងច្បាស់ ។

**ខស្នាន:** ដឹងខ្លះៗអីទេតូ?

**ខន:** បាទ អត់ ។ ប៉ុន្តែអ្នកធំៗអីហ្នឹង ឃើញនៅអញ្ចឹងទៅ ហើយឃើញបាត់មិនដឹងជាទៅឯណា ។

**ខស្នាន:** ខ្ញុំឮថាអ្នកធំៗដូច វ៉ន វេត, កែវ មាស, កុយ ធួន បានជាប់ ស-២១ដែរ ខ្ញុំឮល្ហិចល្ហៀងអញ្ចឹង តូមានដឹងទេ?

**ខន:** ខ្ញុំអត់ស្គាល់ ។

**ខស្នាន:** អាកន្លែងសួរចម្លើយ គេរៀបចំយ៉ាងម៉េចខ្លះ តូលួចមើលឃើញខ្លះទេ?

**ខន:** មាន វ៉ៃ ឮសួរវ៉ៃទូងទាំងៗ ហើយក្រៅពីវ៉ៃ ដាក់ខ្សែភ្លើងឆក់ ។ ក្រៅពីខ្សែភ្លើងមានព្រនង់ឬស្សីឃើញធម្មតា ។

**ខស្នាន:** ខ្ញុំឃើញវត្ថុតាងនៅទួលស្លែង ដូចជាកន្លែងគេចាប់ជ្រមុជទឹក ដាក់ក្អែបអោយខាំដកក្រចក អាហ្នឹងតូដែលឃើញ?

**ខន:** ខ្ញុំមិនអាចឃើញសព្វ ប៉ុន្តែអាចមាន ដូចកន្លែងខ្លះឮថាដកក្រចកដៃ ក្រចកជើង អាហ្នឹងមានដន្លាប់ណា៎ ។

**ខស្នាន:** ដាក់អោយក្អែបខាំ ដែលមាន?

**ខនៈ** អត់ដែលពុទេ។

**ខស្នានៈ** ការសួរចម្លើយ គេមានបែងចែករបៀបសួរទេ? មានប៉ុន្មានរបៀប? ឧបមាថា ប្រភេទសួរអញ្ចេះ ប្រភេទសួរអញ្ចោះទេ?

**ខនៈ** ខ្ញុំបញ្ជាក់ច្បាស់ ក៏មិនអាចច្បាស់បានទេ ព្រោះខ្ញុំនៅផ្នែកបច្ចេកទេសខុសគ្នា ។ ខ្ញុំនៅខាងផ្នែកខាងការពារអញ្ចឹងទៅ ខ្ញុំមិនអាចដឹងកិច្ចការរាក់ជ្រៅខាងសួរទេ អញ្ចឹងបានថាមិនអាចរៀបរាប់បានច្បាស់ទេ។ បើសិនជាខ្ញុំផ្នែកខាងសួរទៅ អាចដឹងច្បាស់ តែដល់ខ្ញុំផ្នែកការពារខាងក្រៅ ប៉ុន្តែអាចដឹងច្បាស់អញ្ចេះ ដឹងថា ឧទាហរណ៍យប់ព្រលប់អី ថ្ងៃណាទំនេរអី ទៅដូរវេនយាមអីមោ៉ ខ្ញុំមកកន្លែងហ្នឹង ក៏អាចខ្ញុំរៀនវ៉ៃអន្តលីលេខអីចឹងទៅណា៎ អញ្ចឹងអាខ្លះក៏យកឯកសារអោយខ្ញុំជួយវ៉ៃដែរ អាឯកសាររឿងរ៉ាវដែលគេសួរនោះណា៎ ប៉ុន្តែគ្រាន់តែថាយូរមក ខ្ញុំមិនអាចចាំអស់ទេ

**ខស្នានៈ** ពូមានដែលអាន ដែលមើល ដូចថាគេអោយវិភាគឯកសារយ៉ាងម៉េច អីយ៉ាងម៉េចទេ?

**ខនៈ** អាហ្នឹងអញ្ចេះ ខ្ញុំមើលឃើញអ្នកនៅបារាយចុងដូង មាននាទីជាប្រធានភូមិ អាហ្នឹងពីលើពីលើមកវាឆ្លើយដាក់ម៉ ហើយគេស្រាវជ្រាវតាមសកម្មភាព ប៉ុន្តែការរៀបរាប់របស់គាត់ មិនដឹងជាឈឺហើយអីហើយក៏មិនដឹងទេ គាត់ឆ្លើយថា គាត់បានដឹកនាំប្រជាជនអោយទៅបំផ្លាញអីចឹងទៅដើម្បីអោយហិនហោចបដិវត្ត ដូចជាទៅស្ទូងស្រូវ......មិនដឹងគាត់ឈឺបេះតែឆ្លើយមិនដឹង គាត់ធ្មើមែនមិនដឹង ខ្ញុំវ៉ៃតាមឯកសារដែលគាត់សរសេរ ដូចថា យកគោក្របី អោយស៊ីស្រូវអញ្ចឹងទៅដើម្បីបំផ្លាញ និយាយសុទ្ធតែគោលបំណងបំផ្លាញតែម្តង។ បើអ្នកបេះឆ្លើយមានសម្រួលតាមបែបតាមបទ តែអ្នកល្ងង់ឆ្លើយមកកំបុតៗតែម្តង សរសេរមកនោះកំបុតៗតែម្តង អាហ្នឹងខ្ញុំវ៉ៃចម្លងឯកសារឃើញមកអញ្ចឹង។

**ខស្នានៈ** មានដែលអ្នកសួរវ៉ៃអ្នកទោស រហូតដល់សន្លប់ ឬងាប់ទេ?

**ខនៈ** មាន ។ មានអាម៉ានគេចាប់នោះ វាវ៉ៃគេងាប់ដែរ ប៉ុន្តែក្រោយមកគេចាប់វិញ មិនដឹងជាទោសហ្នឹង ឬក៏ទោសអីខ្ញុំមិនដឹង ។ ហើយគេចាប់អាចយដែរ ប៉ុន្តែអាចយនោះរត់រួច ។

**ខស្នានៈ** នៅរស់ទេឥឡូវ?

**ខនៈ** នៅនៅ្តើ ។

**ខស្នានៈ** នៅឯណា?

**ខនៈ** ប៉ុន្តែអត់ដឹងនៅឯណាទេ អត់ដែលជួបទេ ។ ប៉ុន្តែដឹងថាគេរួចចេញពីហ្នឹង អាហ្នឹងវ៉ៃគេសាប់ដែរ ។ ដល់វ៉ៃគេសាប់ គេចោទថាសាប់ដាច់ចម្លើយ អត់បានស្រាវជ្រាវអីចឹង ។

**ខស្នាន:** ម៉ានមានដែលកាច់ប្រវ៉ាក់អីរត់ទេ?

**ខនៈ** អត់ទេ ។

**ខស្នាន:** ម៉ានធ្លាប់វ៉ៃគេសាប់ប៉ុន្មាននាក់ដែរ?

**ខនៈ** ឮសួរថាសាប់ ប៉ុន្តែអត់ច្បាស់ថាប៉ុន្មាននាក់ ប៉ុន្មាននាក់ទេ ។ ប៉ុន្តែ ខ្ញុំដឹងតាមអ្នកនិយាយ ។

**ខស្នាន:** ម៉ាន និងលោកពូ តើអ្នកណាមានសិទ្ធិធំជាងអ្នកណាដែរ?

**ខនៈ** មិនដឹងជាអ្នកណាធំជាអ្នកណាទេ ភ្លេចអស់ហើយយូរហើយ ខ្ញុំនិយាយត្រង់ហើយ ។ ប៉ុន្តែកាលណោះវាគួនាទីប្រធានក្រុមការពារមែន ប៉ុន្តែក្រោយមកខ្ញុំដេកពេទ្យអត់ដឹងទេ ដាច់អស់ទៅ ។

**ខស្នាន:** មានដឹងថាម៉ានធ្លាប់ធ្វើយោធាអីនៅកន្លែងណាទេ?

**ខនៈ** ទាហាន ។ ធ្លាប់ធ្វើនៅកងពលជាមួយគ្នាហ្នឹង ។ កងពល១២ ។

**ខស្នាន:** ឃើញម៉ានធ្វើអីនៅកងពល១២?

**ខនៈ** ប្រធានក្រុម អូដូចកងហា អនុសេនាតូច ។ ម៉ានធ្វើប្រធាន ។

**ខស្នាន:** អនុសេនាតូចមានយោធាប៉ុន្មាននាក់?

**ខនៈ** មានបីក្រុម ហើយម៉ាក្រុមគ្នា១២នាក់ ។

**ខស្នាន:** នៅស-២១ ដែលឃើញអ្នកទោសចាមទេ?

**ខនៈ** ដូចមិនបានចាំច្បាស់ទេ ។ គេយក ។ អ្នកទោសមក ដាក់ក្នុងឡានឃុបចុះពីលើឡានមកហុំមុខជិត បានគេបណ្តើរចូលមក ។ ខ្ញុំអត់ដឹងថាអ្នកទោសណាចាម ខ្មែរ យួនទេ អត់ដឹងទេ ។

**ខស្នាន:** ពូនៅម៉ាររយៈពេលនោះ តើឃើញអ្នកទោសប៉ុន្មានរយ ពាន់ ឬម៉ឺននាក់ដែរ? ពូអាចប៉ាន់ស្មានមើលដឹងទេ?

**ខនៈ** ប្រហែលជាមិនដល់ម៉ឺនទេ ។ បើតាមបន្ទប់ខ្ញុំដើរមើលនោះ ច្រើនណាស់ពីរពាន់នាក់ អាហ្នឹងកាលខ្ញុំនៅ ប៉ុន្តែម៉ាររយៈកាលខ្ញុំចេញមក មិនដឹងជាយ៉ាងម៉េចទេ ។ ដល់ពេលខ្ញុំឈឺ ភ្នែកមើលមិនឃើញ ដៃស្ពឹក ជើងស្ពឹក ក្តិចក៏អត់ឈឺ ហើយដកដង្ហើមក៏អត់ ហើយគេបញ្ជូនមកដេកពេទ្យ ពេល

មកដេកពេទ្យ ខ្ញុំចប់សកម្មភាព រហូតដល់វៀតណាមចូល គេហៅចុះពីមន្ទីរពេទ្យមក ចុះទៅជាមួយគេជាមួយឯងទៅ ។ ប ។ "តែពេលរត់ទៅ ស្រួលខ្លួនបន្តិចទៅ មិនធ្វើទុក្ខឯណា ។

**ដានី:** ពូកាលនៅហ្នឹង មានចាប់បានទាហានវៀតណាមយកមកដាក់គុកទួលស្លែងទេ?

**ខន:** ដូចមិនច្បាស់ដែរ ។

**ខស្មាន:** នៅស-២១ របបហូបចុកសម្រាប់អ្នកទោសយ៉ាងម៉េចដែរ?

**ខន:** ហូបចុក ខ្ញុំឃើញបបរលាយដើមចេក ដាក់អំបិល រាវៗទៅ ដាក់ម៉ាវែកៗទៅ..............

.................................ចប់កាសែតទី១ តទៅកាសែតទី២.................................

ដាក់ទៅ ឃើញលើកហុតទៅ អ្នកណាមាត់ធំម៉ាម៉ាត់អស់ហើយ ។

**ខស្មាន:** រយៈពេលមួយថ្ងៃ គេអោយប៉ុន្មានពេល?

**ខន:** ពីរពេល ។

**ខស្មាន:** ពេលណាខ្លះ?

**ខន:** ពេលថ្ងៃត្រង់ និងល្ងាច ។ គេដាក់ប៉ោតវែកយកទៅអោយ ។

**ខស្មាន:** លោកពូនៅហ្នឹង ពេលពូធ្វើកងការពារ ឬធ្វើការងារអ្វីផ្សេងទៀត គេមានអប់រំ ណែនាំយ៉ាងម៉េចដែរ?

**ខន:** រៀងណែនាំ ប្រជុំរាល់ថ្ងៃ ។

**ខស្មាន:** អ្នកណាមកប្រជុំប្រាប់ ។

**ខន:** ដល ។

**ខស្មាន:** ដលស្រុកកំណើតនៅឯណាដែរ?

**ខន:** អត់ដឹងដែរ ។

**ខស្មាន:** ហើយចុះគាណាតយ៉ាងម៉េចវិញ?

**ខន:** គាណាតនៅកងពល១២ ។

**ខស្មាន:** ហើយក្រោយមក មានដឹងថាទៅខាងណាទេ?

**ខន:** គាណាតហ្នឹង ក៏គេចាប់ចូលស-២១ ដែរ ។

**ខស្នាន៖** ចាប់ចូលឆ្នាំណា ៗ ?

**ខន៖** អត់ចាំឆ្នាំទេ ។

**ខស្នាន៖** រឿងអីបានគេចាប់?

**ខន៖** គេស្រាវជ្រាវតាមខ្សែបណ្ដាញគេ ។

**ខស្នាន៖** គាពីនដែលពុទេ?

**ខន៖** គាពីនអនុគាណាគ ។

**ខស្នាន៖** ហើយចុះបន្ទាប់ៗមកទៀត មានឈ្មោះអីទៀត?

**ខន៖** ខ្ញុំអត់ស្គាល់អស់ទេ ។

**ខស្នាន៖** ហើយចុះគាពីន ក្រោយមកយ៉ាងម៉េច?

**ខន៖** គាពីនក៏គេចាប់ ។

**ខស្នាន៖** ពូឃើញទេ គេយកគាណាគមកស-២១?

**ខន៖** អារឿងចាប់មកនោះ វាមិនមែនដាក់ឡូកឡំជាមួយគេដែរ គេដាក់កន្លែងផ្សេងៗ នៅផ្ទះខាងកើត ។

**ខស្នាន៖** ផ្ទះនោះសុទ្ធតែអ្នកទោសធំៗ?

**ខន៖** បាទ ។

**ខស្នាន៖** អ្នកណាអ្នកសួរអ្នកទោសធំៗ?

**ខន៖** ឃើញតែគាចាន់ និងគាឌុច ចូលសួរខ្លួនឯងផ្ទាល់ ព្រោះកិច្ចការគេធំៗណាស់ ។

**ខស្នាន៖** ហើយចុះអ្នកវៃចោល អ្នកធំៗនោះ?

**ខន៖** អត់ដឹងទេ ។

**ខស្នាន៖** អ្នកធំៗដល់គេសួរចម្លើយ គេមានវៃធ្វើបាបទេ?

**ខន៖** បែបមាន ខ្ញុំជឿថាមាន ព្រោះពូសួរគួនក្ដាំងដែរ ខ្លះដាក់ប្រវាក់ជើងអញ្ចឹងណា៎ ឆក់ខ្សែភ្លើងពូសួរផ្ទួនៗក្នុងផ្ទះថ្ម ហើយពូស្រែកអួយៗ ខ្លះពូស្រែកខ្លាំងៗណាស់ ។

**ខស្នាន៖** អ្នកធំ?

**ខន៖** អ្នកធំហ្នឹង ហើយអ្នកតូចក៏ដោយ បើឆក់ស្រែកហើយ ។ រឿងគេសួរចម្លើយអ្នកធំដឹងថាគេសួរហើយ ប៉ុន្តែគិតច្រើនមិនដឹងទេ ហើយដឹងតែគេវៃហើយ ។

**ខស្មាន:** ពូមានចាំឈ្មោះទេ អ្នកធំៗណាខ្លះដែលគេចាប់យកទៅដាក់ ស-២១? ក្រៅពីតាពីន តាណាត។

**ខន:** ខ្ញុំអត់ដឹងដែរ។

**ខស្មាន:** ហើយចុះដូចយ៉ា, កែវ មាស, កុយ ធួន?

**ខន:** ខ្ញុំអត់ស្គាល់ទេ។ ព្រោះជំនាន់នោះបួនមានកើតទាន់ទេ អត់ហ៊ានទៅពិភាក្សាគ្នាទេ អត់ហ៊ានទេ ដេកយប់ បើដេកស្ងៀមហើយ សូម្បីតែប្ដីប្រពន្ធក៏អត់ហ៊ាននិយាយ ដេកយប់ បើដេកប្រិបហើយ សូម្បីតែប្ដីប្រពន្ធក៏អត់ហ៊ាននិយាយគ្នាដែរ។

**ខស្មាន:** សូមពូរៀបរាប់ពីការកិច្ចពូ គេបង្រៀនអោយធ្វើយ៉ាងម៉េចខ្លះ?

**ខន:** គេណែនាំអោយប្រុងប្រយ័ត្ន ក្រែងខ្មាំងវាលបចូល ខ្មាំងវាបោះគ្រាប់មកអីហ្នឹង។

**ខស្មាន:** ចុះប្រធានកងការពារម្នាក់ឈ្មោះហ៊ុយ គាត់នៅខាងកោះធំ គាត់នៅរស់គើរាល់ថ្ងៃនេះ ពូដែលស្គាល់ទេ?

**ខន:** មាន គ្រាន់តែរំលឹកឈ្មោះដឹង ប៉ុន្តែភ្លេច។

**ខស្មាន:** ពូមានដែលស្គាល់ពីណាជាមិត្តភ័ក្រនៅ ស-២១ នៅរស់ដល់រាល់ថ្ងៃនេះទេ?

**ខន:** ខ្ញុំអត់ដែលជួបគ្នាផងតាំងពីបែកមក។ ខ្ញុំឡើងទៅជិតថៃណោះ វៀតណាមដេញរត់ទៅរហូត

**ខស្មាន:** រត់ទៅ ពីណាខ្លះរត់ទៅជាមួយ?

**ខន:** ច្រើនណាស់ កងនារី កងចល័ត មិនដឹងអ្នកណាខ្លះទេ ច្រើនណាស់ រត់តាមព្រៃ។

**ខស្មាន:** ហើយឌុចមានរត់ទៅទេ?

**ខន:** មិនដឹងទៅច្រកណា អីច្រកណាទេ អត់មានជួបគាត់ទេ។

**ខស្មាន:** ពូជួបអ្នកណាខ្លះធំៗ?

**ខន:** ទៅជួបតាម៉ុក។ ជួបតាម៉ុកនៅវត្តស្គរដាច ស្រុកលាជ ខេត្តពោធិសាត់។ ជួបអត់បាន ស្គាល់ទៀតណាំ ប៉ុន្តែគេប្រាប់ នោះតាម៉ុក។ ហើយគាត់ឃើញខ្ញុំ គាត់សួរថា ហ្អែងនៅក្រុមណាំ ហើយខ្ញុំថានៅ៧០៣ កងពល១២គេដូរដាក់៧០៣វិញណា។ ហើយគាត់ថា ហើយចុះហ្អែងធ្វើអី ឯណេះវិញ ខ្ញុំថាខ្ញុំរត់វៀតណាមដេញមក។ ហើយចុះម៉េចបានជារត់? ខ្ញុំថា ខ្ញុំរត់ បើចាញ់គេ មិនរត់។ ឥឡូវហ្អែងប្រមូលកម្លាំងនៅទីនេះហើយ កុំទៅណា ហើយហ្អែងទៅកន្លែងសេដ្ឋកិច្ចសុំអង្ករគេដាំបាយស៊ីទៅ។ ចាំថ្ងៃវៃខ្មែរសជាមួយអញ គាត់ថាអញ្ចឹង។ ដល់ទៅ ទៅវៃខ្មែរស

ជាមួយគាត់មែន ទៅមិនទាន់បានបាញ់អីច្រើន តែម៉ាគ្រាប់ពីរគ្រាប់ ស្រាប់តែរត់អស់ទៅ ។ រួច ហើយខ្ញុំទៅជិតកោះកុង ហើយវៀតណាមវ៉ៃបិទច្រកអស់ទៅ ហើយមកវិញធ្លាក់កំពង់ឆ្នាំង កំពង់ធំ

**ទស្សាន:** តាម៉ុកមកជាមួយគ្នាដែរ?

**ខន:** តាម៉ុកបែកគ្នា មិនដឹងដល់ណាទេ ។ ខ្ញុំជួបតាម៉ុកនៅស្គុជាចតែមួយភ្លែតហ្នឹង ។ ខ្ញុំបកមកវិញ មកចូលសារភាពជាមួយគេនៅកំពង់ធំ ។

**ទស្សាន:** នៅឆ្នាំណា?

**ខន:** ឆ្នាំ៧៩ ។

**ទស្សាន:** សារភាពនៅកន្លែងហ្នុង ខ្ញុំយកកាំភ្លើងអោយគេអស់ទៅ ខ្ញុំគេអប់រំ អោយនៅរៀនសូត្រ ជាមួយវៀតណាមអី ។ ដល់បានកន្លះខែគេធ្វើសំបុត្រមកផ្ទះមក ។ គេអោយអង្កមកសាមសិប គីឡូ អំបិលមួយគីឡូ ធ្វើសោហុយតាមផ្លូវ កាលនោះគេមិនទាន់ចាយលុយ ចាយអីឯណា ។ ខ្ញុំមកដល់ផ្ទះក្នុងឆ្នាំ៧៩ មករកផ្ទះអត់ទាំងឃើញផង ។

**ទស្សាន:** ម៉េចបានជារកផ្ទះអត់ឃើញ?

**ខន:** ចុះបើផ្លែកអស់ហើយ ។

**ទស្សាន:** ហើយចុះបងប្អូនបង្កើត និងឪពុក-ម្តាយមានខ្មែរក្រហមសម្លាប់ដែរទេ?

**ខន:** ឪពុកខ្ញុំនៅ ប៉ុន្តែឪពុកខ្ញុំគេជម្លៀសទៅស្រុកកណ្តាលស្ទឹង ហើយម្តាយខ្ញុំស្លាប់ ស្លាប់ដោយ ជម្ងឺ អត់បាយអត់ទឹក ហើយប្អូនខ្ញុំនៅតែអាមួយពៅទេ ។ ប្អូនខ្ញុំម្នាក់ទៅដីកចង្រិតផ្ទុះគ្រាប់សាវ៉ាន់ ទីណៃងាប់ ហើយពីរនាក់ទៀតបាត់ ។ ហើយឥឡូវនេះ ពុងំណឹងប្អូនខ្ញុំមួយនៅរស់នៅជិតព្រំដែនថៃ ឈ្មោះ ធួន ។ ហើយអាពៅឈ្មោះអារុន ។ ឥឡូវធួនវានៅរកស៊ី ។

**ទស្សាន:** ធួនចូលខាងខ្មែរក្រហមដែរឬអត់ទេ?

**ខន:** ចូល ។ តែដល់ត្រូវរូវគ្នានេះ វានៅខាងរំដោះ កកើតទឹកដីនៅហ្នឹងទៅណា ហើយប្តីវាអីហ្នឹង ខាងណោះទេ(ខាងហ៊ុន សែន) ។ ឥឡូវនៅភូមិកំរៀង ខេត្តបាត់ដំបង ។ ភូមិខ្សែម ស្រុកកំរៀង ។

**ទស្សាន:** ពូក្រៅពីសុន សេន ដូចជានួន ជា, កែវ ពក, អៀង សារី, ប៉ុល ពត មានដែលទាក់ ទងជាមួយ ស-២១ ទេ?

**ខន:** អត់បានដឹងទេ ។

**ទស្សាន:** ពូមានដែលពុឈ្មោះ នួន ជា ទេ?

**ខនៈ** ពុតាមរ៉ាដ្យូ(វិទ្យុ) ។

**ខស្មានៈ** នួន ជាដែលមក ស-២១ ទេ?

**ខនៈ** អត់ដែលទេ ។

**ខស្មានៈ** អ្នកធំៗធ្លាប់មក ស-២១ មានពីណាខ្លះ?

**ខនៈ** និយាយដោយត្រង់ ខ្ញុំឃើញតែសុន សេន ហ្នឹង ចេញចូលៗហ្នឹង ។

**ខស្មានៈ** សុន សេន មកច្រើនដងទេ?

**ខនៈ** ច្រើន ។ អាហ្នឹងវាការងារគេ ទាក់ទងហ្នឹង ។

**ខស្មានៈ** រយៈពេលប៉ុន្មានខែ ឬប៉ុន្មានថ្ងៃ បានគាត់មកម្តង?

**ខនៈ** មិនទៀងទេ ព្រោះបើការងារញឹក គេមកញឹក បើការងាររង្កើល គេមករង្កើលហើយ ។ ប៉ុន្តែ អោយឃើញជាអចិន្ត្រៃយ៍ ។ ។ អត់ទេណា៎ ។ ខ្ញុំឃើញដូចថា ពេលប្រជុំរៀនសូត្រអីហ្នឹងណា៎ ។

**ខស្មានៈ** សុន សេន មកជិះអីមក?

**ខនៈ** សុទ្ធតែឡានស៊ីប ស៊ីបដស់អាមេរិកាំង ។

**ខស្មានៈ** ចុះឌុចពេលទៅណេះទៅណោះអី ជិះអី?

**ខនៈ** ឌុចមានឡាន ។ គាតាន់មានតែម៉ូតូទេ ប៉ុន្តែគាតាន់នោះ មនុស្សកើតស្រែងគំលួងពេញមុខ ទាំងអស់ ដៃក៏ស្រែង ជើងក៏ស្រែង មុខក៏ស្រែង ។

**ដានីៈ** មុខគាត់ដូចកាចទេ?

**ខនៈ** គាត់ដូចសង្ខឹមួយៗ លេងសើចច្រើនគាត់នោះ ។ តាន់នោះ មានហ៊ានលេងសើចខ្លះ ប៉ុន្តែ លេងសើចក្នុងកិច្ចការស្រាលៗទេណា៎ ប៉ុន្តែការងារជ្រៅអត់ហ៊ានទើងគេទេ ។ តាមខ្ញុំដឹងតាឌុច តាតាន់ ខ្សែគាត់ ខ្សែគាត់មកពីខាង.....ដូចជាបងប្អូន ។ ទាំងពីរនាក់ហ្នឹងសុទ្ធតែសាស្ត្រាចារ្យ ។

**ខស្មានៈ** ហើយចុះហ៊ិ?

**ខនៈ** អត់ដឹងប្រវត្តិរូបទេ ។

**ខស្មានៈ** ហ៊ិសាហាវទេ?

**ខនៈ** សាហាវណាស់ មើលអត់បានទេភ្នែកគាត់ ។ ខ្ញុំឃើញខ្លាច ។ ដក់បារីស្ទឹកសន្លឹកប៉ុនៗមេជើង ហ៊ិជិនាន់នោះអាយុ ប្រែប៤០លើស ឥឡូវប្រែបតាហើយ ប៉ុន្តែមិនដឹងនៅឯណា ។ ហ៊ិនោះ ដូចជា

ប្អូនថ្លៃ ឬក៏ក្មួយទេ យកបងប្អូនតាឌុចនោះ គេអ្នកពេញសិទ្ធិ ប្រពន្ធខ្មៅព្រិកហ្នឹង តាចាន់នោះ ប្រពន្ធក៏ខ្មៅ តាឌុចនោះប្រពន្ធក៏ខ្មៅដែរ ខ្មៅ ភ្នែកដូចក្អឹងអញ្ចឹង សក់រួញ។ ស្រុកកំណើតប្រពន្ធតាឌុចនៅត្រពាំងរាំង នៅក្នុងខេត្តកំពង់ស្ពឺ។

**ខស្មាន:** នៅក្នុងឃុំស្រុកណា។ ?

**ខន:** មិនដឹងឃុំស្រុកអីទេ នៅជិតភ្នំអាលាក់កង់ដើង ហួសឱរ៉ាល់ទៅទៀត។ នៅត្រង់ជ្រលងភ្នំ។

**ខស្មាន:** រាល់ថ្ងៃប្រពន្ធនៅរស់ទេ?

**ខន:** អត់ដឹង។ ខ្ញុំដឹងព្រោះ ថ្ងៃកាលរត់ទៅហ្នឹង ឆ្លងកាត់ផ្លូវហ្នឹងណា ហើយគេថា នេះ នេះ ស្រុកប្រពន្ធតាឌុច។ ត្រង់ហ្នឹងវាជាប់ព្រំប្រទល់ខេត្តពោធិសាត់ហើយ។

**ខស្មាន:** ក្រៅពីហ្នឹងមានស្គាល់អ្នកណាទៀតទេ អ្នកធំៗនៅ ស-២១?

**ខន:** នៅស-២១ មានតែឌុច ចាន់ ហ៊ី ហ្នឹងហើយ?

**ខស្មាន:** ហើយចុះ ទុយ ប៉េង?

**ខន:** ដូចដែលអត់ដែលព្វទេ។

**ខស្មាន:** ចុះម៉ាំនធំទេ?

**ខន:** ម៉ាំនហ្នឹងមានធំស្អី បើថាធំបំផុតប្រធានសួរចម្លើយ។

**ខស្មាន:** ប្រធានសួរចម្លើយមានសិទ្ធិធំដែរឬ?

**ខន:** អាហ្នឹងវាមានសិទ្ធិតែក្នុងហ្នឹង។

**ខស្មាន:** អ្នកសួរចម្លើយវៃអ្នកទោសហ្នឹង តើមានបទបញ្ជារពីឌុចដែរ ឬក៏អត់ទេ?

**ខន:** អាហ្នឹងគេដាក់បទបញ្ជារមកហើយ អោយសួរបើមិនឆ្លើយ វៃ។ ខ្ញុំមិនបានព្វបទបញ្ជារនោះទេ គ្រាន់តែខ្ញុំស្មាន ព្រោះពេលយកមកសួរគ្មានអ្នកណាទៅហ្នឹង ហើយព្វសួរគេវៃ អាហ្នឹងមានតែអញ្ចឹង។

**ខស្មាន:** ខ្ញុំមានប្រវត្តិរូបមួយចង់អោយពូមើល។ នេះ អ្នកទោសគេធ្វើប្រវត្តិរូប ឬយ៉ាងម៉េច (បង្ហាញប្រវត្តិរូបអ្នកទោសឈ្មោះ ម៉ី ម៉ាត់ ដែលជាអ្នកទោសខនបានសួរ)។

**ខន:** នេះមានលេខ ២៨។

**ខស្មាន:** មានលេខអញ្ចឹងមែន?

**ខន:** បែបមាន។ នៅភូមិថ្មី ឃុំខ្សាច់អណ្ដែត ស្រុកឆ្លូង តំបន់ ២១។ ឆ្លូងក្រចេះឯណោះ?

**ខស្មានៈ** បាទ ។

**ខនៈ** នៅឆ្ងាយណាស់ ខ្ញុំមិនស្គាល់ទេ ។

**ខស្មានៈ** ពូព្យាយាមនឹកមើលមើ នេះខ្ញុំសូមជំរាបពូត្រង់ថា នៅក្នុងឯកសារចម្លើយសារភាពរបស់ ម៉ើ ម៉ាត់ ហ្នឹង មានឈ្មោះលោកពូជាប់ក្នុងហ្នឹងដែរ យ៉ាងម៉េចបានជាមានឈ្មោះលោកពូជាប់ក្នុងហ្នឹងដែរអញ្ចឹង?

**ខនៈ** នៅឯណា?

**ខស្មានៈ** គឺនៅក្នុងចម្លើយសារភាពរបស់ឈ្មោះ ម៉ើ ម៉ាត់ នេះ ។ នេះខ្ញុំយកអោយលោកពូមើល ។ នេះនៅត្រង់នេះ មានឈ្មោះលោកពូ (បង្ហាញឯកសារចម្លើយសារភាពដែលគាត់(ខន) បានសួរ ចង្អុលប្រាប់ត្រង់ មានចុះហត្ថលេខារបស់គាត់ និងឈ្មោះរបស់គាត់ថា "អ្នកសួរ ប្រាក់ ខន") ម៉េចបានជាមានឈ្មោះលោកពូអញ្ចឹង?

**ខនៈ** នៅលើគំរបទេតើ ។

**ខស្មានៈ** ប៉ុន្តែនៅខាងក្រោមៗទៀតដូចជាមានដែរ (បើកបង្ហាញអោយគាត់មើលគ្រប់ទំព័រចម្លើយសារភាពរបស់ឈ្មោះ ម៉ើ ម៉ាត់ ដែលមានចុះហត្ថលេខា និងឈ្មោះរបស់គាត់ ថាជាអ្នកសួរ) ។ ពូអាចចាំទេ ក្រែងលោពូធ្លាប់មើលឯកសារនេះដែរ?

**ខនៈ** អាហ្នឹងប្រហែលជា អ្នកដែលខ្ញុំធ្លាប់វៃអង្គុលីលេខ និងមើល ។

**ខស្មានៈ** ពូ អ្នកទោសគេអោយស៊ីញ៉េគ្រប់ទំព័រយ៉ាងនេះឬ?

**ខនៈ** ស៊ីញ៉េឯណា?

**ខស្មានៈ** នេះ សុទ្ធតែស៊ីញ៉េទាំងអស់ ។

**ខនៈ** ខ្ញុំគេអាចអោយកត់ត្រា កត់ចម្លង មាន ។ មានម្តងម្កាលដែរ ។ ខាងកត់ចម្លងមាន ។

**ខស្មានៈ** ហើយចុះអក្សរនេះ ជាអក្សរអ្នកណា?

**ខនៈ** (គាត់ឈប់មួយសន្ទុះ ទើបឆ្លើយ) អូ ខ្ញុំនឹកឃើញហើយ អ្នកទោសអាខ្លះអក្សរស្អាត អាខ្លះអក្សរអត់សូវស្អាត ហើយគេអោយខ្ញុំកត់ចម្លង អាខ្លះកត់ចម្លងអង្គុលីលេខទៅ អាខ្លះកត់ចម្លងដៃ ហើយដល់ខ្ញុំអ្នកកត់ចម្លង ដាក់អ្នកសួរតែម្តងទៅ ហើយស៊ីញ៉េទៅ ហើយបញ្ជូនអោយគេទៅមានអញ្ចឹង ។

**ខស្មានៈ** ហើយចុះឯកសារនេះ គេយកទៅខាងណាវិញ?

**ខនៈ** កាលនោះឯកសារខ្ញុំប្រគល់អោយមេក្រុម ។

**ខស្មាន:** ហើយអានេះ ជាអក្សរអ្នកណាលោកពូ (បង្ហាញអក្សរនៅលើចម្លើយសារភាព ដែលគាត់អះអាងថាអក្សរគាត់កត់ចម្លង និងបង្ហាញអក្សរលើប្រវត្តិរូបរបស់គាត់ដែលគាត់អះអាងពីដំបូងថាគាត់សរសេរខ្លួនឯង)?

**ខនៈ** (គាត់ចង្អុលលើចម្លើយសារភាព) អានេះមិនមែនអក្សរខ្ញុំទេ ព្រោះមិនដូចគ្នា (មិនដូចអក្សរក្នុងប្រវត្តិរូបរបស់គាត់) ។

**ខស្មាន:** ហើយចុះអាកន្លែងសញ្ញាខ្វែងនេះ បានន័យថាម៉េច(បង្ហាញសញ្ញាខ្វែងត្រង់កម្លាំងក្បត់) អាកន្លែងសញ្ញាខ្វែងនេះ បញ្ជាក់ថាម៉េចដែរ?

**ខនៈ** អាហ្នឹងឈ្មោះគេចាប់ហើយ ។

**ខស្មាន:** ចុះឈ្មោះដែលមិនទាន់មានសញ្ញាខ្វែង?

**ខនៈ** អាហ្នឹងគេអត់ទាន់ចាប់ទេ ។

**ខស្មាន:** អាហ្នឹងគេចាប់ហើយ គេចាប់យកមកដាក់ ស-២១ ដែរឬយ៉ាងម៉េច?

**ខនៈ** តាមចម្លើយគេឆ្លើយ មិនដឹងជាចាប់ដាក់ឯណាទេ នេះមើលត្រង់នេះ ។

**ខស្មាន:** កន្លែងនេះសរសេរថា "សរសេរចប់នៅថ្ងៃ២២ ខែ១-៧៧" អញ្ចឹងបានន័យថា គេអោយសរសេរ គឺសរសេរច្រើនដង? ហើយត្រង់នេះ មានដាក់ "លើកទី២" ទៀត?

**ខនៈ** អូ ចម្លើយមិនដឹងជាប៉ុន្មានដងទេ ទំរាំតែគេយក អោយសរសេរទាល់តែអស់ចិត្ត យកមកចម្លងអោយគេនោះឡើងខ្ចិល ។

**ខស្មាន:** ខ្ញុំសូមជម្រាបលោកពូថា បើលោកពូមានឈ្មោះយ៉ាងម៉េចៗនេះ សូមពូកុំបារម្ភអីថាមានគេមករករឿងលោកពូអីនោះ អត់មានទេ ខ្ញុំជាអ្នកការពារលោកពូផ្ទាល់ ខ្ញុំធានា មិនអាច..... ព្រោះបើមានការរកយុត្តិធម៌មែន គេកាត់ទោសតែអ្នកធំៗ គឺអ្នកដឹកនាំនយោបាយនោះតែម្តង ត្រឹមតែកូនចៅតូចតាច បើយើងមិនធ្វើអញ្ចឹង គេសម្លាប់យើងដែរ ។

**ខនៈ** ជនាន់នោះ បើអ្នកយល់អញ្ចឹងបានដឹង បើអ្នកមិនយល់ ចង់កំហឹងនោះ មិនដឹងទេ ។ ខ្ញុំនៅចំណោមនោះហើយ បើខ្ញុំមិនធ្វើ អញ្ចឹងប្អូនឯងសុខចិត្តទេ ឧទាហរណ៍ប្អូនឯងត្រួតត្រាលើខ្ញុំនោះ បើខ្ញុំមិនធ្វើ អញ្ចឹងដូចខ្ញុំនិយាយពីឈ្មោះម៉ានហ្នឹងអញ្ចឹង សកម្មភាពនោះដូចជាសកម្មភាពប្រឆាំងនឹងគេ អញ្ចឹងខ្ញុំមិនត្រូវស្លាប់វិញ ។ អញ្ចឹងដោះស្រាយម៉ាពេលសិនទៅនៅក្នុងដំណាក់កាលនោះ

ប៉ុន្តែក្រោយមកខ្ញុំលែងហើយ ខ្ញុំកែប្រែវិញ ខ្ញុំដឹងខ្លួនថាខ្ញុំខុស ខ្ញុំមិនអនុវត្តទៀតទេ ព្រោះអារឿងនោះ ខ្ញុំដឹងថារឿងវាធំណាស់ ខ្ញុំមិនអាចនិយាយកើតហ្នឹង រឿងហ្នឹងអញ្ចឹង ។ ប៉ុន្តែក្នុងនេះ ខ្ញុំត្រូវតែនិយាយ មិននិយាយយ៉ាងម៉េច ព្រោះថារឿងសកម្មភាពរបស់ខ្ញុំ ប៉ុន្តែអោយខ្ញុំនិយាយតែលក្ខណៈខ្ញុំដឹង ខ្ញុំធ្វើ តែក្នុងលក្ខណៈខ្ញុំអត់ធ្វើ អត់ដឹង ខ្ញុំនិយាយអត់កើតដែរ ។

**ខស្នាន:** ដូចខ្ញុំជម្រាបលោកពូមិញអញ្ចឹង សូមលោកពូកុំភិតភ័យថា លោកពូអាចត្រូវគេសង្ស័យយ៉ាងម៉េចគ្មានទេ ខ្ញុំជាអ្នកធានាលោកពូផ្ទាល់ក្នុងរឿងហ្នឹង ។ ខ្ញុំមិនអោយលោកពូភិតភ័យអីទេ ដូចថាក្នុងការកាត់ទោសអ្នកណាម្នាក់អញ្ចឹង ទាល់តែមានសាក្សី ហើយសាក្សីអ្នកណាដែលឆ្លើយគឺមានតែអ្នកដែលធ្លាប់ធ្វើការជាមួយគ្នាកាលពីជំនាន់នោះទេ បានដឹងពីនយោបាយគេយ៉ាងម៉េច ។ ឧបមាថាទៅសួរអ្នកណាដែលគេចាប់បងប្អូន ឬឪពុក-ម្តាយ អត់ដឹងពីនយោបាយគេយ៉ាងម៉េច បានដឹងថាគេមកចាប់តែប៉ុណ្ណឹងទេ ។ ប៉ុន្តែអ្នកដែលដឹងរឿងនោះផ្ទាល់គឺជាអ្នកដែលនៅក្រោមបញ្ជារគេ ។ អញ្ចឹងកាលណា បើមានតុលាការខ្មែរក្រហមមែន គេកាត់ទោសតែអ្នកធំៗទេ ។ ដូចឥឡូវតាម៉ុក និងឌុចគេឃុំខ្លួនបណ្តោះអាសន្នហើយ ។ ខ្ញុំមានរូបថតឌុច ។

**ខន:** ឃើញស្គាល់ឥឡូវហ្នឹង ធ្មេញស្ញេញ ។

..............................អស់កាសែតខាង«អេ» តទៅខាង«ប៊ី»..............................

**ខស្នាន:** នេះរូប អៀង សារី ។

**ខន:** អៀង សារី ខ្ញុំស្គាល់ ។ ព្រោះអញ្ចេះ ខ្ញុំនិយាយអោយអស់ ។ កាលខ្ញុំនៅហ្នុង ថ្ងៃណាគេត្រូវការកងការពារពិសេស អោយទៅរាវមីន អើវាមានភ្ញៀវបរទេសមកកន្លែងអគ្គសេនាធិការ កន្លែងចំការមន កន្លែងបញ្ជារកងទ័ពនៅដេអិននេះ អញ្ចឹងគេអោយកម្លាំងខ្ញុំទៅរាវមីន រាវតាំងពីផ្លូវចូល រាវតាំងពីពូកកៅអី គ្រែព្រំខ្នើយអី គឺរាវទាំងអស់ អញ្ចឹងខ្ញុំជួបស្គាល់ហើយ ។

**ខស្នាន:** បាននិយាយរកគ្នាទេ?

**ខន:** អត់ទេ ។ ខ្ញុំស្អប់គាំភ្លើងហើយ បើពីណាអោយក៏ខ្ញុំអត់យកដែរឥឡូវនេះ ។ អារឿងនេះ បើប្អូនមិនប្រាប់ខ្ញុំ ក៏ខ្ញុំអាចស្មែងយល់បានខ្លះដែរ ប៉ុន្តែ ខ្ញុំដឹងថា បើយ៉ាងណាមួយៗ ក៏ប្អូនឯងការពារអោយដែរ ។ បើអ្នកមិនល្អត្រឹមត្រូវ គេមិនមកអញ្ចឹងទេ ខ្ញុំនឹកឃើញថាអញ្ចឹងហើយ ។

ហើយនិយាយត្រង់ រឿងហ្នឹងក៏រឿងត្រូវលាក់ការណ៍ដែរ ខ្ញុំមកនេះ ក៏ខ្ញុំមិនដែលនិយាយប្រាប់អ្នកណាផង ។

**ប្រពន្ធខន:** តែខ្ញុំមិនបានដឹងអីផង ។

**ខន:** ប្រវត្តិខ្ញុំដូចរចត់ណាស់ ខ្ញុំកែប្រែ ខ្ញុំតូចចិត្តខ្លួនឯងណាស់និយាយត្រង់ ប៉ុន្តែក្រោយពីហ្នឹងមក ខ្ញុំមិនដែលធ្វើអំពើអាក្រក់ទៀតទេ ខ្ញុំរកស៊ីដោយសុចរិត កាលហ្នឹងច្បាប់របស់គេវាអញ្ចឹងហើយ បើខ្ញុំមិនធ្វើអញ្ចឹង មិនកើត ។

**ខស្មាន:** ខ្ញុំយល់ ខ្ញុំយល់ហើយរឿងហ្នឹង ខ្ញុំបានជួបសុទ្ធតែមេធំៗ គាត់ក៏សុទ្ធតែទទួលបញ្ជារពីថ្នាក់លើដែរ ហើយបញ្ជារនោះតឹងរឹងណាស់ ។

**ខន:** អានឹងហើយ ខ្ញុំនិយាយនោះ ។ ខ្ញុំនឹកឃើញស្តាយណាស់ ធ្វើការគ្មានបានផលប្រយោជន៍អីទេ ។

**ខស្មាន:** បើសិនជាថ្ងៃក្រោយទៅ មានតុលាការមួយរកយុ ។ ត្តិធម៌អោយប្រជាជន លោកពូហ៊ាន ធ្វើកស្សិណសាក្សីនិយាយប្រាប់គេថា កាលពូនៅគុកទួលស្លែងបានទទួលបញ្ជារពីអ្នកនេះអ្នកនោះ ហើយបានឃើញសកម្មភាពយ៉ាងនេះយ៉ាងនោះទេ?

**ខន:** ដូចខ្ញុំនិយាយប្រាប់អញ្ចឹង បើខ្ញុំឃើញជាក់ស្តែងអញ្ចឹងមែន ខ្ញុំខ្លាចអីហ្នឹងនិយាយ កុំអោយតែ យកខ្ញុំទៅឃុំឃាំង ។

**ខស្មាន:** អត់ទេ បើមានរឿងហ្នឹងខ្ញុំធានា ។

**ខន:** ប្អូនឯងធានាអញ្ចឹង ប៉ុន្តែបើថ្ងៃក្រោយអោយអ្នកផ្សេងមក ។ បើចង់ធានាខ្ញុំ ប្អូនឯងមានវត្ថុតាងអីអាចអោយខ្ញុំជឿទុកចិត្តបាន?

**ខស្មាន:** លោកពូកុំបារម្ភ ។

**ខន:** មិនបារម្ភយ៉ាងម៉េច បើថ្ងៃនេះទៅប្អូនឯងទៅបាត់ ខ្ញុំនៅឯនេះ ថ្ងៃក្រោយអោយអ្នកផ្សេងមក អានេះយើងនិយាយអញ្ចេះ យើងនិយាយការពារជាដែកគ្នាអាក្រក់អោយហើយបានល្អក្រោយ ។

**ខស្ថាន:** ខ្ញុំអោយលេខទូរស័ព្ទ ខ្ញុំអោយអាស័យដ្ឋានខ្ញុំ។ ហើយបើថ្ងៃក្រោយ គេមករករឿង លោកពូអី លោកពូទូរស័ព្ទប្រាប់ខ្ញុំ ខ្ញុំមកភ្លាម។ សូម្បីតែឌុច ត្រូវបានចាប់ខ្លួន ប៉ុន្តែឌុចផ្សេង ពូផ្សេង មិនអាចប្រៀបធៀបថាដូចគ្នាកើតទេ។
**ខន:** ត្រូវហើយ ឌុចខ្ពស់ណោះ ខ្ញុំខ្ពស់នេះ ប្រៀបធៀបម៉េចកើត។